# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបាត់ដំបង

លេខ: ២៥០៦ / សជណ /២៤

## សេចក្តីជូនដំណឹង
## ស្តីពីដាក់ឱ្យដេញថ្លៃភាសុីគ្រប់ប្រភេទ ក្នុងខេត្តបាត់ដំបង សម្រាប់ធ្វើអាជីវកម្ម ឆ្នាំ២០២៥

@@@@@@

## អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង

-យោងលិខិតលេខ១០៦២៣ សហវ.លស.អទច ចុះថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំរៀបចំដាក់ឲ្យដេញថ្លៃភាសុីគ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ តាមនីតិវិធីដេញថ្លៃជាសាធារណៈ និងជំរុញការប្រមូលចំណូលបង់ចូលថវិការាជធានី ខេត្ត។

-យោងសេចក្តីសម្រេចលេខ ១៤៩/២៤ ចុះថ្ងៃចន្ទ១១រោចខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២៤ របស់រដ្ឋបាលខេត្តបាត់ដំបង ស្តីពីការបង្កើតគណៈកម្មការរៀបចំការដេញថ្លៃភាសុី គ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្ម ឆ្នាំ២០២៥

## សូមជម្រាបជូនដំណឹង

ដល់សាធារណៈជន ទូទាំងខេត្តបាត់ដំបង ឱ្យបានជ្រាបថា៖

១-រដ្ឋបាលខេត្តបាត់ដំបង សូមប្រកាសដាក់ឱ្យដេញថ្លៃភាសុីគ្រប់ប្រភេទសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៥ រយៈពេល១២ខែ តាមនីតិវិធីដេញថ្លៃជាសាធារណៈ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង នាថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៨:០០ នាទីព្រឹកតទៅ ដែលមានទីតាំងភាសុី ដូចខាងក្រោម ៖

| ល.រ | មូលដ្ឋានផ្សារ | ភាសុីដាក់ឱ្យដេញថ្លៃ | តំលៃមូលដ្ឋាន (ឯកត្តារៀល) | ផ្សេងៗ |
|---|---|---|---|---|
| I | ភាសុីផ្សារ | | 135,000,000 | |
| ១ | ស្រុកឯកភ្នំ | ផ្សារសាលាតាអន,ផ្សារប្រហុក,ផ្សារព្រែកកញ្ជ្រោង,ផ្សារសំរោងក្នុង,ផ្សារព្រែកខ្ពប និងផ្សារពាមឯក | 23,000,000 | |
| ២ | ស្រុករតនមណ្ឌល | ផ្សារដំណាក់ស្តៅ | 10,000,000 | |
| ៣ | ស្រុកសង្កែ | ផ្សារសង្កែ,ផ្សារអន្លង់វិលចាស់,ផ្សារ | 35,000,000 | |

អាសយដ្ឋាន: ផ្លូវលេខ០១, ទល់មុខស្ពានថ្មចាស់, ទូរស័ព្ទ និងទូរសារលេខ: ០៥៣ ៧៣៩ ៩៩៩/ ៧៣៩ ៩៩៩ គេហទំព័រ: www.battambang.gov.kh
Address : Road 01, In front of old bridge, Telephone & Fax : 053 739 999 / 739 999 Website: www.battambang.gov.kh
អ៊ីម៉ែល / Email: info@battambang.gov.kh Facebook Page : រដ្ឋបាលខេត្តបាត់ដំបង: www.facebook.com/battambang.gov.kh

| | | | | |
|---|---|---|---|---|
| | | អូរដំបង,ផ្សារស្វាយធំ និងផ្សារវត្តតាមិម | | |
| ៤ | ស្រុកបវេល | ផ្សារឃុំខ្នាចរមាស | 3,500,000 | |
| ៥ | ស្រុកបាណន់ | ផ្សារបាណន់,ផ្សារឈើទាល;ផ្សារភ្នំសំពៅ និងផ្សារស្ទឹង | 19,000,000 | |
| ៦ | ក្រុងបាត់ដំបង | ផ្សារសង្កាត់ក្តុលដូនទាវ | 4,000,000 | |
| ៧ | ស្រុកគាស់ក្រឡ | ផ្សារឃុំគាស់ក្រឡ | 1,000,000 | |
| ៨ | ស្រុកសំពៅលូន | ផ្សារសំពៅលូន | 3,000,000 | |
| ៩ | ស្រុកកំរៀង | ផ្សារស្រុកកំរៀង | 3,500,000 | |
| ១០ | ស្រុកភ្នំព្រឹក | ផ្សារភ្នំព្រឹក | 3,000,000 | |
| ១១ | ស្រុកបវេល | ផ្សារបវេល | 30,000,000 | |
| II | **ចំណតយានជំនិះ:** | | **10,000,000** | |
| ១២ | ស្រុកបវេល | | 10,000,000 | |
| **សរុបរួម** | | | **145,000,000** | |

២-ពលរដ្ឋទាំងពីរភេទដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ (លើកលែងតែមន្រ្តីរាជការ,និយោជិត, សិស្ស និងនិស្សិត) ដែលមានកំណត់ក្នុងប្រការ៥ នៃសៀវភៅបន្ទុក) មានបំណងចង់ប្រកបមុខរបរធ្វើអាជីវកម្មភាស៊ីក្នុង ឆ្នាំ២០២៥ ខាងមុខនេះ សូមអញ្ជើញមកចុះឈ្មោះ និងដាក់ពាក្យចូលដេញថ្លៃនៅការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង តាមពេលម៉ោងធ្វើការជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

៣-ចំពោះសាធារណៈជនដែលដាក់ពាក្យដេញថ្លៃចាំបាច់ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនដូចខាងក្រោម៖

ក-បង់ប្រាក់កក់បណ្តោះអាសន្នចំនួន ២០% នៃតម្លៃមូលដ្ឋាន ដោយកក់ទីតាំងណា អនុញ្ញាតិឱ្យចូលរួមដេញថ្លៃ តែទីតាំងនោះប៉ុណ្ណោះមិនអនុញ្ញាតិឱ្យចូលដេញថ្លៃទីតាំងដ៏ទៃដែលអតិថិជន មិនបានបង់ប្រាក់កក់នោះទេប្រាក់កក់បណ្តោះអាសន្នត្រូវបង់នៅរតនាគារខេត្តបាត់ដំបង ជាប្រាក់រៀល យ៉ាងយូរត្រឹមថ្ងៃទី ១៩ខែ វិច្ឆិកា ឆ្នាំ២០២៤ ជាកំណត់ ។

ខ-ចំពោះធនធាន ឬអចលនវត្ថុធានា ចំនួន៥០% នៃតម្លៃមូលដ្ឋាន ត្រូវមានការវាយតម្លៃបញ្ជាក់អំពីមេឃុំ ចៅសង្កាត់ ហើយប្លង់កម្មសិទ្ធិឬធនធានត្រូវតែយករបស់បេក្ខជនផ្ទាល់មិនអនុញ្ញាតិឱ្យយកប្លង់កម្មសិទ្ធិរបស់អ្នកដទៃមកជំនួសឡើយ ។ ករណីបេក្ខជនជាក្រុមហ៊ុនត្រូវបញ្ជាក់ពីម្ចាស់កម្មសិទ្ធិ និង មានការយល់ព្រមពី គណៈកម្មការដេញថ្លៃភាស៊ីខេត្ត។

គ-អ្នកដាក់ពាក្យចូលរួមដេញថ្លៃ ដែលមិនបានចូលដេញថ្លៃដោយគ្មានមូលហេតុ ឬក្នុងមូលហេតុដែលមិនអាចទទួលយកបានឬប្រកែកពុំព្រមចូលដេញថ្លៃនោះ ប្រាក់កក់បណ្តោះអាសន្ន ២០%នៃតម្លៃមូលដ្ឋានរបស់អាជីវករ នឹងត្រូវរឹបអូសជាប្រយោជន៍ថវិកាខេត្តទាំងស្រុង ។

ឃ-ពាក្យចូលដេញថ្លៃ នឹងចាប់ទទួលនៅការិយាល័យទ្រព្យសម្បត្តិរដ្ឋនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២៤ វេលាម៉ោង ១៥:០០ ល្ងាច ជាកំណត់ ។

ង-ចំពោះព័ត៌មានផ្សេងៗទៀត សូមអញ្ជើញទំនាក់ទំនងនៅ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ។

អភិបាលនៃគណៈអភិបាលខេត្ត និងគណៈកម្មការរៀបចំការដេញថ្លៃភាស៊ីគ្រប់ប្រភេទ មានសង្ឃឹម និងជឿជាក់យ៉ាងមុតមាំ ថាសាធារណៈជន និងអតិថិជនទូទាំងខេត្តពិតជាចូលរួមយ៉ាងផុសផុលបំផុត ក្នុងដំណើរការដេញថ្លៃភាស៊ីគ្រប់ប្រភេទ នាឆ្នាំនេះបានល្អប្រសើរជាមិនខាន ។

ថ្ងៃ ចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

បាត់ដំបង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

**អភិបាលខេត្ត**

**សុខ លូ**

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាខេត្ត

*ដើម្បីគោរពជូនជ្រាប*
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាលាក្រុង-ស្រុកពាក់ព័ន្ធ
- មន្ទីរព័ត៌មានខេត្តផ្សព្វផ្សាយ(តាមវិទ្យុនិងទូរទស្សន៍)
- ឯកសារ-កាលប្បវត្តិ